ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថាប័នប្រឆាំងអំពើពុករលួយ
**អង្គភាពប្រឆាំងអំពើពុករលួយ**

លេខ ០០៧/១៥ ស.រ.ណ ........... អ.ប.ព.

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥

**សេចក្តីប្រកាសព័ត៌មានករណីពាក្យប្តឹងលេខ ៨៦៩/១៣ ពាក់ព័ន្ធនឹងឯកឧត្តម ឧត្តមសេនីយ៍ត្រី សោម បុប្ផារ័ត្ន មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងព្រះវិហារ**

អង្គភាពប្រឆាំងអំពើពុករលួយបានទទួល និងពិនិត្យលើពាក្យប្តឹង ដែលបានចោទប្រកាន់ថា ឯកឧត្តម ឧត្តមសេនីយ៍ត្រី ***សោម បុប្ផារ័ត្ន*** មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងព្រះវិហារ ពាក់ព័ន្ធនឹងភាពមិនប្រក្រតីក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ឯកឧត្តម។ ការបំភ្លឺពីឯកឧត្តម ឧត្តមសេនីយ៍ត្រី ***សោម បុប្ផារ័ត្ន*** មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងព្រះវិហារ គួបផ្សំនឹងការស្រាវជ្រាវរបស់អង្គភាពប្រឆាំងអំពើពុករលួយគឺមានលទ្ធផលដូចខាងក្រោម៖

១. ដីលក់នៅតំបន់ជាំស្រងាំមានពិតតែជាដីរបស់ឯកឧត្តម **ជា ម៉ន** មេបញ្ជាការយោធភូមិភាគទី៤ ដែលមានទំហំ ៤០ម៉ែត្រ x ៨០ម៉ែត្រ លក់បានតម្លៃ **១២.០០០ដុល្លារ** កាលពីឆ្នាំ២០០៦ តែលុយនេះត្រូវបានឯកឧត្តម **ជា ម៉ន** បរិច្ចាគយកមកកសាងអង្គភាព គួបផ្សំ និងថវិកាសប្បុរសជនផ្សេងទៀត ដូចមាន៖

- ពង្រីកសាលប្រជុំពី ៨ម៉ែត្រx២០ម៉ែត្រ ទៅ ៩ម៉ែត្រ x ២៤ម៉ែត្រ។
- សាងសង់ក្លោងទ្វារថ្មីចូលទីបញ្ជាការ និងរបងបេតុងដែលមានប្រវែង ១១០ម៉ែត្រ កម្ពស់២ម៉ែត្រ។
- កសាងខឿនដងទង់ជាតិ និងសួនច្បារបង្គោលភ្លើងខាងមុខសាលប្រជុំប្រវែង ១២៨ ម៉ែត្រ។
- កសាងអគារធ្វើការអំពីថ្មដែលមានទំហំ ៦ម៉ែត្រ x ១២ម៉ែត្រ ចំនួន ៥ខ្នង អគារឈើ ៦ ម៉ែត្រ x ១២ម៉ែត្រ ចំនួន៨ខ្នង និងឃ្លាំងបេតុង ៨ម៉ែត្រ x ២០ម៉ែត្រ ចំនួន១ខ្នង។

២. ការចោទប្រកាន់ថា អង្គភាពតំបន់ប្រតិបត្តិការសឹករងព្រះវិហារ មានលួចលក់ដីរបស់អង្គភាពនៅតំបន់អានសេះ អង្គភាពប្រឆាំងអំពើពុករលួយរកឃើញថា អង្គភាពនេះគ្មានដីនៅតំបន់អានសេះនោះទេ។

សូម **ម្ចាស់បណ្តឹង** ជ្រាបជាព័ត៌មាន។

**អង្គភាពប្រឆាំងអំពើពុករលួយ**